**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបើក
## សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំឆ្នាំ២០២៤

**ថ្ងៃព្រហស្បតិ៍ ៦រោច ខែកត្តិក ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨**
**ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤**
**នៅទីស្តីការគណៈរដ្ឋមន្ត្រី**

- សូមគោរពអង្គពិធីទាំងមូល
- ឯកឧត្តម លោកជំទាវ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋានរាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!

ថ្ងៃនេះ ជាថ្មីម្តងទៀត ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកធ្វើជាអធិបតីក្នុងពិធីបើកសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២៤ បន្ទាប់ពីកិច្ចប្រជុំពេញអង្គដែលបានប្រព្រឹត្តទៅកាលពីព្រឹកម្សិលមិញ។ ក្នុងឱកាសដ៏ប្រពៃនេះ ខ្ញុំសូមសម្តែងនូវការស្វាគមន៍ និងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានដ៏មានតម្លៃរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងលើកទិសដៅសកម្មភាពសម្រាប់ឆ្នាំ២០២៥ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជារបស់យើង។

ក្នុងរយៈពេលមួយឆ្នាំនេះ យើងបានបំពេញភារកិច្ចយ៉ាងសកម្មរួមគ្នា ដើម្បីឈានទៅបញ្ចប់ការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងដំណាក់កាលដែលស្ថានភាពប្រាកដប្រជា ភាពប្រឈម រួមនឹងនិន្នាការធ្លាក់ចុះនៃហិរញ្ញប្បទានក្រៅប្រទេស។ នៅក្នុងរយៈពេលផ្ទេរដំណាក់កាលនេះយើងទាំងអស់គ្នាចាប់ផ្តើមបំពេញតួនាទីក្នុងភាពជាម្ចាស់រួមនឹងការពង្រឹងភាពជាអ្នកដឹកនាំ ជាពិសេសទំនួលខុសត្រូវរបស់

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមបណ្ដា ក្រសួង ស្ថាប័ន រាជធានី ខេត្ត រួមជាមួយអង្គការដៃគូ ក្នុងការពង្រីកសក្ដានុពលនៃបទអន្តរាគមន៍នានា ក៏ដូចជាធ្វើការសិក្សាស្រាវជ្រាវ និងជំរុញលើកទឹកចិត្តអ្នកសង្ស័យថាផ្ទុកមេរោគអេដស៍ ឱ្យមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ដើម្បីឈានឆ្ពោះទៅសម្រេចបានគោលដៅ៩៥ទីមួយ។

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីសុឆន្ទៈនយោបាយដ៏មោះមុតឆ្ពោះទៅសម្រេចបាននូវគោលដៅ និងការបញ្ចប់ការគំរាមកំហែងពី មេរោគអេដស៍ និងជំងឺអេដស៍ ក្រោមមាគ៌ាដឹកនាំប្រកប ដោយគតិបណ្ឌិត និងស្វាហាប់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការចូលរួមគាំទ្រយ៉ាងសកម្ម ទូលំទូលាយ និងពហុវិស័យពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន អ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ។

ក្នុងខែមេសា ឆ្នាំ២០២៣ កន្លងទៅនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល/មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការ UNAIDS បានរួមគ្នាផ្សព្វផ្សាយការប៉ាន់ប្រមាណមេរោគអេដស៍ចុងក្រោយបង្អស់របស់កម្ពុជា ដែលទទួលបានលទ្ធផលគួរជាទីគាប់ចិត្ត។ ទោះជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែង និងការវិនិយោគ គួរត្រូវបានផ្ដោតគោលដៅលើការកាត់បន្ថយការឆ្លងថ្មីក្នុងចំណោមបុរស ការលុបបំបាត់ការចម្លងពីម្ដាយទៅកូន កុមារដែលផ្ទុកមេរោគអេដស៍ ជាមួយនឹងសេវាកម្មនានាទាំងក្នុងផ្នែកសុខាភិបាល និងផ្នែកមិនមែនសុខាភិបាល។

ការបង្ការនៅតែជាបញ្ហាប្រឈម ក្នុងខណៈពេលដែលការព្យាបាលបានគ្របដណ្ដប់កម្រិតខ្ពស់ និងការប្ដេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបំពេញគម្លាតនៅក្នុងគោលដៅ៩៥ ទី១។ មានការកើនឡើងនូវសមាមាត្រនៃការឆ្លងថ្មីក្នុងចំណោមយុវវ័យ ដែលមានរហូតដល់ ៤៣%។ ការយល់ដឹងពីមេរោគអេដស៍និងជំងឺអេដស៍ នៅមានកម្រិតទាប ការរួមភេទជាក្រុមដោយប្រើប្រាស់គ្រឿងញៀន (Chemsex) កំណើននៃការណាត់ជួបតាមអ៊ីនធឺណិត និងតាមបណ្ដាញទាក់ទងផ្លូវភេទ កម្រិតទាបនៃការប្រើប្រាស់ស្រោមអនាម័យ និងអត្រាប្រេវ៉ាឡង់ខ្ពស់នៃជំងឺកាមរោគ បានធ្វើឱ្យយុវវ័យប្រឈមនឹងហានិភ័យ និងធ្វើឱ្យពួកគេងាយឆ្លងមេរោគអេដស៍។ ផ្នែកបង្ការនៅតែមានការខ្វះហិរញ្ញប្បទាន ដែលជាកត្តារារាំងដល់ការខិតខំប្រឹងប្រែងជាពហុវិស័យក្នុងការបញ្ឈប់ការឆ្លងថ្មី និងការរកឱ្យឃើញអ្នកទើបតែឆ្លងថ្មីដើម្បីទទួលបានការព្យាបាលក្នុងពេលតែមួយ។ ការបង្ការក៏ផ្ដោតតែលើការរកឱ្យឃើញករណីជាជាងការបង្កើននូវចំណេះដឹង និងការយល់ឃើញពីហានិភ័យ ព្រមទាំងការផ្លាស់ប្ដូរការប្រព្រឹត្តិ ដែលអាចឱ្យក្រុមប្រជាជនគន្លឹះ និងយុវជនអាចបង្ការខ្លួនបាន។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិកសមាជិកាអង្គសន្និបាតជ្រាបថា នៅក្នុងអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នាពេលនេះយើងនឹងមានរបៀបវារៈចំនួន៦ ដើម្បីធ្វើបទបង្ហាញជូនអង្គសន្និបាត រួមមាន៖

ទី១- បទបង្ហាញស្ដីពី៖

- ទិន្នន័យ Community Led Monitoring ( CLM) ដើម្បីពន្លឿនដំណោះស្រាយឆ្ពោះទៅសម្រេចគោលដៅ៩៥-៩៥-៩៥ បង្ហាញជូនដោយតំណាងFONPAM
- ឥរិយាបថប្រឈមរបស់យុវវ័យ បង្ហាញជូនដោយតំណាងប្រជាជនគន្លឹះវ័យក្មេង

- វិធីសាស្ត្រទប់ស្កាត់ការចម្លងមេរោគអេដស៍ ម=ម បង្ហាញជូនដោយ **លោក សឿម សុផល**
- អាទិភាពរបស់ក្រុមFONPAMសម្រាប់ឆ្នាំ២០២៥ បង្ហាញជូនដោយតំណាងFONPAM។

ទី២- បទបង្ហាញស្តីពី ៖

- បទពិសោធន៍នៃការប្រើប្រាស់ហិរញ្ញប្បទានក្នុងស្រុកសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅខេត្តព្រៃវែង បង្ហាញជូនដោយប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រៃវែង
- បទពិសោធន៍នៃការប្រើប្រាស់ហិរញ្ញប្បទានក្នុងស្រុកសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅរាជធានីភ្នំពេញ បង្ហាញជូនដោយប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ។

ទី៣- បទបង្ហាញស្តីពីលទ្ធផលបឋមនៃការវាយតម្លៃកម្មវិធីបង្ការមេរោគអេដស៍ជាពហុវិស័យ ក្នុងប្រទេសកម្ពុជាបង្ហាញជូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំមានជំនឿថា អង្គសន្និបាតរបស់យើងនឹងទទួលបានចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗបានមកពីការអនុវត្តជាក់ស្តែង របស់សមាជិក សមាជិកានៃអង្គសន្និបាត ដែលអាចយកទៅប្រើប្រាស់ក្នុងការកែលម្អនិងអនុវត្តកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅតាម ក្រសួង ស្ថាប័ន រាជធានី ខេត្ត របស់ខ្លួនឱ្យបានកាន់តែល្អប្រសើរថែមទៀត។ នៅក្នុងរបៀបវារៈចុងក្រោយ តាមរយៈសុន្ទរកថាបិទ ខ្ញុំនឹងផ្តល់ចំណាប់អារម្មណ៍រួមលើលទ្ធផលនៃអង្គសន្និបាត រួមជាមួយអនុសាសន៍មួយចំនួនដើម្បីយកទៅអនុវត្តសម្រាប់ឆ្នាំ ២០២៥ បន្តទៀត ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ ការពិភាក្សា និងការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងចំណោមសមាជិក សមាជិកានៃអង្គសន្និបាត ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅពេលនេះ និងសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ មានសុខភាពល្អ កម្លាំងមាំមួនក្នុងការចូលរួមពិភាក្សាឱ្យបានផុសផុល ដើម្បីទទួលបាននូវលទ្ធផលទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក "**សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៤**" ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***